ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣៤៨ ឧវឧក-អវជក.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារដឹកនាំ និងជំរុញឌីជីថលូបនីយកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារដឹកនាំ និងជំរុញឌីជីថលូបនីយកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សរសេរអក្សរកាត់ថា ក.ដ.ឌ. ដែលមានសមាសភាពដូចខាងក្រោម៖



៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | ហែម វណ្ណឌី | រដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម | ញឹម ខេមរា | រដ្ឋលេខាធិការប្រចាំការ | អនុប្រធានប្រចាំការ |
| ៣. | ឯកឧត្តម | កាន ច័ន្ទមេត្តា | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. | ឯកឧត្តម | ដាវ អានសាន | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥. | ឯកឧត្តម | ហ៊ុល សៀងហេង | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៦. | ឯកឧត្តម | ង៉ែត វិបុល | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម | សមាជិក |
| ៧. | ឯកឧត្តម | ពៅ វណ្ណដា | អគ្គនាយកនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | សមាជិក |
| ៨. | ឯកឧត្តម | តន់ សុខដា | អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត | សមាជិក |
| ៩. | ឯកឧត្តម | ចាន់ សូផា | អគ្គនាយកនៃវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ១០. | ឯកឧត្តម | ប៊ី ពិទូរ្យ | ប្រធានមជ្ឈមណ្ឌលនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ១១. | ឯកឧត្តម | ជៀន សេងគង់ | អគ្គនាយកនៃអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់ នៃកម្ពុជា | សមាជិក |
| ១២. | ឯកឧត្តម | តាន់ សុវិទ្យា | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៣. | លោកជំទាវ | ពេជ សុរិយា | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ១៤. | ឯកឧត្តម | ទ្រី សុផល | អគ្គនាយកនៃអគ្គនាយកដ្ឋាន រ.ប.ន. | សមាជិក |
| ១៥. | ឯកឧត្តម | កែវ សុជាតិ | អគ្គនាយកនៃវិទ្យាស្ថានជាតិ រ.ប.ន. | សមាជិក |
| ១៦. | លោកស្រី | សេង មូលិកា | ប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន រ.ប.ន. នៃអគ្គនាយកដ្ឋាន រ.ប.ន. | សមាជិក |
| ១៧. | លោក | ចិន សុវណ្ណ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន រ.ប.ន. នៃអគ្គនាយកដ្ឋាន រ.ប.ន. | សមាជិក |
| ១៨. | លោក | ទេព សុវណ្ណ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន រ.ប.ន. នៃអគ្គនាយកដ្ឋាន រ.ប.ន. | សមាជិក។ |

**ប្រការ២.-**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃ អំពីតម្រូវការនៃការប្រើប្រាស់ប្រព័ន្ធឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្នុងការគ្រប់គ្រង និងការបំពេញមុខងាររបស់អង្គភាពក្រោមឱវាទរបស់ក្រសួង
- ដឹកនាំ រៀបចំ និងដាក់ចេញផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ជំរុញឌីជីថលូបនីយកម្មរបស់ក្រសួង
- ដឹកនាំ រៀបចំ និងដាក់ចេញផែនការថវិកាសម្រាប់គាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ជំរុញឌីជីថលូបនីយកម្មរបស់ក្រសួង

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ជំរុញឌីជីថលូបនីយកម្មរបស់ក្រសួង
- ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃអំពីកម្រិតសមត្ថភាពរបស់មន្ត្រីរាជការ និងបុគ្គលិកក្រសួងលើការគ្រប់គ្រង ការប្រើប្រាស់ និងអភិវឌ្ឍន៍ ប្រព័ន្ធឌីជីថល
- ដឹកនាំ រៀបចំ និងដាក់ចេញផែនការបណ្តុះបណ្តាល និងបំពាក់បំប៉នសមត្ថភាពលើជំនាញគ្រប់គ្រង ប្រើប្រាស់ និងអភិវឌ្ឍ ប្រព័ន្ធឌីជីថល ដល់មន្ត្រីរាជការ និងបុគ្គលិកដែលបម្រើការងារនៅក្រសួង
- សម្របសម្រួល និងសហការ ជាមួយក្រសួង-ស្ថាប័ន ឬអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីជំរុញឌីជីថលូបនីយកម្មនៅក្រសួង ឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- បំពេញភារកិច្ចផ្សេងទៀតតាមការចាំបាច់ ដើម្បីជំរុញឌីជីថលូបនីយកម្មនៅក្រសួង។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកនៃក្រុមការងារនេះ ត្រូវចូលរួមក្នុងកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចកោះប្រជុំ ឬដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

ក្រុមការងារនេះ អាចជ្រើសរើសមន្ត្រីក្រោមឱវាទបន្ថែម ដើម្បីជាជំនួយដល់ការអនុវត្តការងាររបស់ខ្លួន។

ក្រុមការងារនេះ អាចអញ្ជើញអ្នកជំនាញ ទីប្រឹក្សា ឬមន្ត្រីជំនាញ ពីក្រសួង-ស្ថាប័ន ឬអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ចូលរួមផ្តល់យោបល់ ឬជួយដល់ដំណើរការការងារពាក់ព័ន្ធនឹងការជំរុញឌីជីថលូបនីយកម្មនៅក្រសួង តាមការចាំបាច់។

**ប្រការ៤.-**

**ក.ជ.ឌ.** មាន **អង្គភាពបរិវត្តកម្មឌីជីថល** ជាលេខាធិការដ្ឋាន។

សមាសភាពតួនាទី និងភារកិច្ចនៃ**អង្គភាពបរិវត្តកម្មឌីជីថល** ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែក។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធានមន្ទីរ ឧ.រ.ប.ន. រាជធានី-ខេត្ត គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ